**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

SOCIAL PROTECTION IN CAMBODIA

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី២៥)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ១០ ៥៩២ នាក់ នៃរោងចក្រ សហគ្រាស ទាំង៤៣ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរស័ព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ៦០ ៧៥០រៀល (១៥ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២១ ៥០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៤៣ នេះ មិនបានទទួលសារទូរស័ព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមប្រញាប់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ ពុធ ៨កើត ខែ ភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ សីហា ឆ្នាំ២០២០

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

**ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០**

**បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍**
**ចំនួន ៤៣ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល**

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 31 |
| 1 | ក្រុមហ៊ុន អេឃើនថិច ភីធីអ៊ី | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ស្កាយវើត ហ្វេសិន (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 3 | ក្រុមហ៊ុន ស៊ីកូ(ភ្នំពេញ)ខូអិលធីឌី | ភ្នំពេញ |
| 4 | ក្រុមហ៊ុន វូ ដុង អ៊ីនដាសស្ទ្រៀល | ភ្នំពេញ |
| 5 | ក្រុមហ៊ុន នីវ ហ្គេង ឌី (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 6 | ក្រុមហ៊ុន ខូហ៊ីស្គ(ខេមបូឌា) | ភ្នំពេញ |
| 7 | ក្រុមហ៊ុន ហូយៀ (ខេមបូឌា) ហ្គាមេន លីមីធីត | ភ្នំពេញ |
| 8 | ក្រុមហ៊ុន អាន់ហ៉រឈើនព្រីនធីន ឯ.ក | ភ្នំពេញ |
| 9 | ក្រុមហ៊ុន អ៊ីហ្ស៊ី ឡាហ្វ៍ ស៊ូ ឯ.ក | ភ្នំពេញ |
| 10 | ក្រុមហ៊ុន វី.ស៊ី.អូ.អេហ្វ.អេហ្វ អីភែរីល ឯ.ក | ភ្នំពេញ |
| 11 | ក្រុមហ៊ុន ជីនវីន អ៊ីនដាសស្ទ្រី ខេមបូឌា ខូអិលធីឌី | កណ្តាល |
| 12 | ក្រុមហ៊ុន មីង ហ្វៃ អេនធើប្រាយ (ខេមបូឌា) ឯ.ក. | កំពង់ស្ពឺ |
| 13 | ក្រុមហ៊ុន ចិចសាន់(ខេមបូឌា)នីតធីង វ៉ស៊ីង ដាយអ៊ីង អេន ព្រីនធីង ឯ.ក | កំពង់ស្ពឺ |
| 14 | ក្រុមហ៊ុន ស៊ុយ យ៉ាត អេ (ខេបូឌា)ខូអិលធីឌី | កំពង់ស្ពឺ |
| 15 | ក្រុមហ៊ុន សូអា ផ្លាសថយ (ខេមបូឌា) ខូ អិល ធី ឌី | កំពង់ស្ពឺ |
| 16 | ក្រុមហ៊ុន ហ្វ្រេត ភីស លីមីធីត | កំពង់ស្ពឺ |
| 17 | ក្រុមហ៊ុន វីកូតិច អ៊ិនដាសស្ទ្រៀល ខូ អិលធីឌី | កំពង់ស្ពឺ |
| 18 | ក្រុមហ៊ុន ហាន វ៉េ (ខេមបូឌា) ឯ.ក | កំពង់ស្ពឺ |
| 19 | ក្រុមហ៊ុន ផាតធេច(ខេមបូឌា)ឯ.ក | កំពង់ស្ពឺ |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
| --- | --- | --- |
| 20 | ក្រុមហ៊ុន ភីវី អ៊ិនដាសស្ទ្រី(ខេមបូឌា)ឯ.ក | តាកែវ |
| 21 | ក្រុមហ៊ុន ហាជ័រអ៊ិនធើណេសិនណល(ខេមបូឌា)ឯ.ក | តាកែវ |
| 22 | ក្រុមហ៊ុន យូហ្វី ថេលើរ ខបភើរេសិន | តាកែវ |
| 23 | ក្រុមហ៊ុន អេតា អ៊ីកែវីល ឯ.ក | តាកែវ |
| 24 | ក្រុមហ៊ុន ហ៊ីវ៉ាយហ្សិន អៅដរ(ខេមបូឌា)ខូ,.អិលធីឌី_1 | កំពង់ឆ្នាំង |
| 25 | ក្រុមហ៊ុន យឺងម៉េកឃើ(ខេមបូឌា)ហ្វូតវែរ | ស្វាយរៀង |
| 26 | ក្រុមហ៊ុន កៅវ៉េ ស្ព័ត អិលធីឌី | ស្វាយរៀង |
| 27 | ក្រុមហ៊ុន ជីនចេនយ័ន(ខេមបូឌា) | ព្រះសីហនុ |
| 28 | ក្រុមហ៊ុន ណាតផាក (ខេមបូឌា) ឯ.ក | ព្រះសីហនុ |
| 29 | ក្រុមហ៊ុន ខេមបូឌាន សាន់វ៉ាយ៍ ហ្គាមេន ខូអិលធីឌី | ព្រះសីហនុ |
| 30 | ក្រុមហ៊ុន អិលខេ ឡាក់ហ្គេដ | ព្រះសីហនុ |
| 31 | ក្រុមហ៊ុន ញូវ ស្ការ ស៊ូ ខូអិលធីឌី | ព្រះសីហនុ |
| ខ. វិស័យទេសចរណ៍ | | 12 |
| 32 | សណ្ឋាគារ ហ្គាឌិន ស៊ីធី | ភ្នំពេញ |
| 33 | ក្រុមហ៊ុន កូបេ យៃកែននីស រេស្តូរ៉ង់ | សៀមរាប |
| 34 | ផ្ទះសំណាក់ ឌីណាតា អង្គរ | សៀមរាប |
| 35 | ក្រុមហ៊ុន រ៉ូយ៉ាល់អង្គរ (សណ្ឋាគារសូហ្វីតែលអង្គរភូគីត្រាហ្គោហ្វ & ស្ប៉ារីហ្សត) | សៀមរាប |
| 36 | សណ្ឋាគារ តារា អង្គរ | សៀមរាប |
| 37 | ក្រុមហ៊ុន អេមព្រីស អង្គរ | សៀមរាប |
| 38 | សណ្ឋាគារសោមាទេវីអង្គររីសត & ស្ប៉ា | សៀមរាប |
| 39 | ក្រុមហ៊ុន ដឹ អេរៀរី | សៀមរាប |
| 40 | ក្រុមហ៊ុន ភូមិបៃតង (ខេមបូឌា) | សៀមរាប |
| 41 | ក្រុមហ៊ុន អានឡុង អេហ្សេត អ៊ិវេសមេន | សៀមរាប |
| 42 | ក្រុមហ៊ុន ទន្លេសាបចៅផាយ៉ា( ភោជនីយដ្ឋានទន្លេសាប) | សៀមរាប |
| 43 | សណ្ឋាគារ សាឯមសៀមរាប | សៀមរាប |